NON-TIMBER FOREST PRODUCTS ORGANIZATION

# គោលនយោបាយ

# ប្រឆាំងអំពើពុករលួយ

# Anti-Corruption Policy

Final Approval date: October 2016

**Vision**

Indigenous people in Cambodia exercise their rights and effectively participate in the development of the national society, in using and managing their land and natural resources for their sustainable livelihood, and maintenance of their culture identity.

**Mission**

To promote indigenous communities, both women and men, to effectively and equitably participate in decision making to choose their own future, especially to assure their rights in sustainably managing, using and development their land and natural resources that are the basis of their livelihood and for conserving their culture.

**NTFP Address**

*4Village, Labansek commune, Banlung District, Ratanakiri Province, Cambodia.*

*Office Phone:*

*(855) 75 974 039*

*P.O Box 89009*

*NTFP registered with the Ministry of Interior on 18th May 2007*

## តារាងមាតិកា


| លរ | មាតិកា | ទំព័រ |
|---|---|---|
| ១. | សេចក្តីណែនាំ | ១ |
| ១.១ | គោលបំណងនៃឯកសារនេះ | ១ |
| ១.២ | វិសាលភាព | ១ |
| ១.៣ | និយមន័យនៃអំពើពុករលួយ | ២ |
| ១.៤ | វាក្យស័ព្ទបច្ចេកទេស | ២-៥ |
| ២. | គោលនយោបាយមិនអនុគ្រោះ (ZERO TOLERANCE) | ៥ |
| ៣. | សកម្មភាពរបស់អង្គការ NTFP ក្នុងការបង្ការការប្រព្រឹត្តអំពើពុករលួយ | ៥ |
| ៣.១ | វិធានការទូទៅ | ៥-៦ |
| ៣.២ | សកម្មភាពរបស់កម្មវិធី | ៦-៩ |
| ៤. | ទណ្ឌកម្ម | ៩-១០ |

## ១.សេចក្ដីណែនាំ

គោលនយោបាយនេះរៀបរាប់អំពីវិធានការរបស់អង្គការអនុផលព្រៃឈើដើម្បីការពារកុំអោយមានអំពើពុករលួយកើតឡើងក្នុងកំឡុងពេលអនុវត្តសកម្មភាពរបស់គម្រោង។ ភាគច្រើននៃការចាត់វិធានការនៃការការពារទុកជាមុនដែលបានបង្ហាញនៅទីនេះមានរួចមកហើយ,ប៉ុន្តែឯកសារទាំងនេះផងដែរបានបង្ហាញពីវិធានការនៃការការពារថ្មីៗរាល់ហានិភ័យនិងវិធានការគួរត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងចំណោមបុគ្គលិកទាំងអស់។

គោលនយោបាយនេះត្រូវបានរៀបរៀងឡើងក្រោមការជួយជ្រោមជ្រែង,ពិគ្រោះយោបល់និងអនុម័តដោយក្រុមប្រឹក្សាភិបាល។

### ១.១ គោលបំណងនៃឯកសារនេះ

គោលនយោបាយនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើជាឯកសារបំពេញបន្ថែមគោលនយោបាយផ្សេងៗទៀតរបស់អង្គការអនុផលព្រៃឈើ(NTFP)។គោលបំណងសំខាន់នៃគោលនយោបាយនេះគឺដើម្បីបង្ការ និងលុបបំបាត់ការប្រព្រឹត្តអំពើពុករលួយ នឹងបង្កើតបរិយាកាសធ្វើការដែលមានតម្លាភាព និងភាពស្មោះត្រង់ នៅក្នុងអង្គការNTFP។

### ១.២ វិសាលភាព

គោលនយោបាយនេះអនុវត្តចំពោះបុគ្គលជាបុគ្គលិកនៃអង្គការNTFP រួមទាំងនាយកអ្នកគ្រប់គ្រងជាន់ខ្ពស់ បុគ្គលិកសាកល្បង បុគ្គលិក និងបុគ្គលិកបណ្ដោះអាសន្ន អ្នកហាត់ការអ្នកស្ម័គ្រចិត្ត ទីប្រឹក្សា និងបុគ្គលិកពាក់ព័ន្ធផ្សេងទៀត ក្នុងអំឡុងពេលបម្រើការងារឱ្យអង្គការNTFP ។ អង្គការNTFP មានគោលនយោបាយតម្រូវឱ្យបំពេញការងារគ្រប់យ៉ាង ប្រកបដោយភាពស្មោះត្រង់ មានវិជ្ជាជីវៈ និងគោរពក្រមសីលធម៌ ។ អង្គការNTFPមិនអត់ឱនចំពោះបុគ្គលិកទាំងឡាយណាដែលប្រព្រឹត្តិអំពើពុករលួយ ។

១.៣ និយមន័យនៃអំពើពុករលួយ

[1]អង្គការNTFPកំណត់និយមន័យអំពើពុករលួយថា ជាការប្រើប្រាស់ខុសនូវអំណាច ដែលប្រគល់អោយ ឬមូលនិធិដែលត្រូវបានប្រគល់ជូន ដើម្បីជាប្រយោជន៍ឯកជនណាមួយ របស់ខ្លួនឯង ឬ ជាប្រយោជន៍នៃក្រុមគ្រួសារ មិត្តភ័ក្រ្ត សហការី ហើយអំពើនោះត្រូវបាន បញ្ញត្តិដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៃប្រទេសកម្ពុជា។

១.៤ វាក្យស័ព្ទបច្ចេកទេស

ក្នុងការពិភាក្សាអំពីការប្រតិបត្តិអំពើពុករលួយ ពាក្យមួយចំនួនដែលមានសារសំខាន់។[2]

•ការសូក(Bribery): ត្រូវបានកំណត់ថាជា″ ការឱ្យ ការផ្តល់ឱ្យ ការទទួលឬការអែអង្គាស ដោយផ្ទាល់ឬមិនផ្ទាល់នូវវត្ថុមានតម្លៃអ្វីមួយដែលមានឥទ្ធិពលមិនត្រឹមត្រូវលើសកម្មភាពនៃភាគីម្ខាងទៀត។″ មានន័យថាបុគ្គលម្នាក់បានបង់អ្វីមួយ(សំណូក) ទៅឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីឱ្យមានឥទ្ធិពលលើការសម្រេចចិត្តរបស់ជននោះ។

•ការឆបោក(Fraud): ជា″អំពើណា ឬការខកខាន រួមបញ្ចូលការថ្លែងបោកប្រាស់ ដែលនាំឱ្យយល់ច្រឡំ ឬប៉ុនប៉ងធ្វើឱ្យយល់ច្រឡំ ដោយដឹងឬដោយទ្វេសប្រហែស ភាគីណាមួយទទួលបានផលប្រោជន៍ហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍ផ្សេងទៀត ឬ ដើម្បីជៀសវាងពីកាតព្វកិច្ចណាមួយ ″។ បុគ្គលដែលព្យាយាម ដោយចេតនា ធ្វើឱ្យបុគ្គលម្នាក់ផ្សេងទៀតយល់ច្រឡំ ដើម្បីទទួលបានផលប្រយោជន៍។ឥរិយាបថដែលធ្វើឱ្យយល់ច្រឡំនេះអាចត្រូវប្រព្រឹត្តឡើងដោយផ្តល់ព័ត៌មានខុស (រួមទាំងការផ្តល់ព័ត៌មានពាក់ព័ន្ធមិនពេញលេញ។ )

---

[1] គោលនយោបាយប្រឆាំអំពើពុករលួយរបស់មូលនិធិជំនួយប្រជាជន Norwegian

[2] ធនាគារពិភពលោក (២០០៦) អត្ថាធិប្បាយអត្ថន័យនៃពាក្យទាំងនេះ ប៉ុន្តែបញ្ជាក់អំពីពាក្យទី១ (ការសូក)ជា ″ អំពើពុករលួយ″។ NTFP ជឿជាក់ថាពាក្យទាំងអស់នេះបង្ហាញពីទម្រង់ខុសៗគ្នានៃអំពើពុករលួយ(យោងសេចក្តីណែនាំស្តីពីការបង្ការ ការប្រយុទ្ធប្រឆាំងនឹងអំពើឆបោក និងអំពើពុករលួយ នៅក្នុងគំរោងផ្តល់ហិរញ្ញប្បទានដោយ IBRD Loans និង IDA Credits and Grants, ទីក្រុងWashington D.C, 15 តុលា 2006)

•ការក្លែងបន្លំ(Forgery): ជាការ " ធ្វើ ដកហូត ឬក្លែង ឯកសារណាមួយក្នុងគោលបំណងដើម្បីឆបោក។ ហត្ថលេខាណាមួយដែលត្រូវបានធ្វើតាម ដោយមិនឱ្យបុគ្គលនោះដឹង ឬយល់ព្រម " ។ អំពើក្លែងបន្លំតាមការពិតជាទម្រង់នៃការឆបោកដែលភាគច្រើនជាអំពើល្មើសច្បាប់ព្រហ្មទណ្ឌ។ វាមានន័យថាថាឯកសារថ្មីត្រូវបានបង្កើត ឬឯកសារដែលមានស្រាប់ត្រូវបានផ្លាស់ប្តូរក្នុងគោលបំណងប្រព្រឹត្តអំពើឆបោក។

•ការបង្ខិតបង្ខំ (Coercion): ជា"ការធ្វើឱ្យទន់ខ្សោយ ឬការធ្វើឱ្យខូចប្រយោជន៍ ឬការគំរាមកំហែងដើម្បីធ្វើឱ្យទន់ខ្សោយឬអន្តរាយ ដោយផ្ទាល់ឬមិនផ្ទាល់ ដល់ភាគីណាមួយ ឬទ្រព្យសម្បត្តិរបស់ភាគីណាមួយ ក្នុងគោលបំណងធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយដោយមិនត្រឹមត្រូវ "។ មនុស្សម្នាក់ព្យាយាមធ្វើឱ្យមានឥទ្ធិពលលើអ្នកធ្វើសេចក្តីសម្រេចចិត្តណាមួយតាម

រយៈការដាក់សម្ពាធលើជននោះ។

•ការឃុបឃិត (Collusion): ជា"ការរៀបចំរវាងភាគីពីរ ឬច្រើននាក់ ដែលចាត់ចែងឡើងដើម្បីសម្រេចបាននូវគោលបំណងមិនត្រឹមត្រូវ រួមមានការធ្វើឱ្យឥទ្ធិពលដោយមិនត្រូវលើសកម្មភាពរបស់ភាគីមួយផ្សេងទៀត "។ ការឃុបឃិត តាមធម្មតា និងជាទូទៅ ជាករណីដែលអ្នកម៉ៅការមួយចំនួនលើកគម្រោងតម្លៃរបស់ខ្លួនសម្រាប់កិច្ចសន្យាណាមួយដោយចេតនាដើម្បីធានាថាអ្នកម៉ៅការមួយ ផ្តល់តម្លៃថោកបំផុត។ តាមរយៈការសហការគ្នានៅក្នុងវិធីនេះពួកគេបានធានាថាពួកគេទាំងអស់ទទួលបាននូវចំណែកនៃទីផ្សារ។

•ការរារាំង (Obstruction): ជា"ការបំផ្លាញដោយចេតនា ការភូតកុហក ការក្លែង ការកែ ឬការលាក់បាំង នូវភស្តុតាងសំខាន់ ចំពោះការស៊ើបអង្កេត ឬការធ្វើសេចក្តីថ្លែងការណ៍មិនពិតទៅក្រុមអ្នកស៊ើបអង្កេត ក្នុងគោលបំណងសំខាន់ រារាំងដល់ការស៊ើបអង្កេតណាមួយ"។ ការអនុ

វត្ថុអំពើពុករលួយដូចនេះកើតឡើងក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត(ឬពេលខ្លះដើម្បីជៀសវាងការស៊ើបអង្កេត) នៅពេលដែលភស្តុតាងត្រូវបានបំផ្លាញ។

•ការបង់ប្រាក់ដោយខុសច្បាប់ (Kickback): ជាទម្រង់មួយនៃការសូក នៅពេលដែលជនណាមួយជាប់ពាក់ព័ន្ធក្នុងដំណើរការទិញទទួលបានរង្វាន់ពីអ្នកផ្គត់ផ្គង់សម្រាប់ការបញ្ជាទិញទំនិញឬសេវា។

•ការកែបំបាត់ (Embezzlement): អំពើចោរកម្មលើធនធានហិរញ្ញវត្ថុ ឬសម្ភារៈសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់។

•ការបំផ្លាញភស្តុតាង (Evidence destruction): ការបំផ្លាញ ការដកយកចេញ, ឬការរំលោភបំពានលើកំណត់ត្រាដោយខុសពីវិធានធម្មតា។

•ការជំរិតទារប្រាក់ (Extortion): អំពើទទួលបានអ្វីមួយដោយការបង្ខិតបង្ខំ ការគំរាមកំហែង ឬការទាមទារ ដោយមិនត្រឹមត្រូវ។

•ការលំអៀងលើមនុស្សជំនិត (Favoritism): ការលំអៀងដោមិនត្រឹមត្រូវលើបុគ្គលមួយ ឬក្រុមមួយ ក្នុងចំណោមមនុស្សនានា (រួមទាំងញាតិពន្ធនិយមដែលលំអៀងទៅខាងសាច់ញាតិ)។

•ការខកខានមិនរាយការណ៍ពីអំពើពុករលួយដោយដឹង (Knowingly omitting to report corrupt acts): ការខកខាន ដោយចេតនា ឬការបដិសេធក្នុងការរាយការណ៍ ឬធ្វើសកម្មភាពតាមការរាយការណ៍អំពីភាពខុសពីវិធានធម្មតា ឬ អាកប្បកិរិយាមិនស្មោះត្រង់ណាមួយ។

•ការគ្រប់គ្រងមិនល្អ (Maladministration): ការគ្រប់គ្រងមិនល្អ ឬការប្រព្រឹត្តខុសខាងហិរញ្ញវត្ថុនៅក្នុងការចាត់ចែង ឬរាយការណ៍អំពីប្រាក់កាស ប្រតិបត្តិការហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិផ្សេងទៀត។

អំពើពុករលួយមិនទាមទារឱ្យអំពើខុសច្បាប់ទាំងនេះ ត្រូវបានបញ្ចប់ឬទទួលបានជោគជ័យតាមគោលបំណងរបស់ពួកគេឡើយ។ សូម្បីតែមិនទាន់បានបញ្ចប់ ឬបរាជ័យក្នុងការប្រព្រឹត្តក៏ត្រូវចាត់ទុកថាជាការប្រព្រឹត្តអំពើពុករលួយដែលត្រូវជៀសវាងដែរ។ ក្នុងបណ្តាប្រទេសភាគច្រើនសកម្មភាពបែបនេះ (ជោគជ័យឬមិនជោគជ័យ) គឺត្រូវផ្តន្ទាទោសដោយច្បាប់។ ឧទាហរណ៍ដូចជាការផ្តល់ជូននូវប្រាក់សំណូក ទៅឱ្យភាគីមួយទៀតបង្កើតបានជាការប្រតិបត្តិអំពើពុករលួយ និងអាចត្រូវផ្តន្ទាទោស ទោះបីជាសំណូកមិនត្រូវបានទទួលយកឬមិនទទួលយក ឬគោលបំណងនៃសំណូកនោះត្រូវបានសម្រេចឬមិនសម្រេចក៏ដោយ។

## ២.គោលនយោបាយមិនអនុគ្រោះ (ZERO TOLERANCE)

NTFP អនុវត្តឥរិយាបថមិនអនុគ្រោះ ចំពោះការប្រព្រឹត្តអំពើពុករលួយ។ មានន័យថា NTFP បដិសេធមិនទទួលយករាល់អាកប្បកិរិយាទាំងឡាយដែលអាចចាត់ជាអំពើពុករលួយ។

រួមជាមួយគ្នានេះដែរ NTFPប្តេជ្ញាក្នុងការតាមដាន ស៊ើបអង្កេត និងចោទប្រកាន់ករណីពុករលួយដែលត្រូវបានរកឃើញ យ៉ាងពេញលេញ ទៅតាមនីតិវិធីជាធរមាន ដោយធ្វើការពិចារណាលើកំរិតធ្ងន់ធ្ងរនៃករណីនេះ ក៏ដូចជាច្បាប់ក្នុងស្រុកផងដែរ។

## ៣. សកម្មភាពរបស់អង្គការ NTFP ក្នុងការបង្ការការប្រព្រឹត្តអំពើពុករលួយ

៣.១ វិធានការទូទៅ

- ជារៀងរាល់ឆ្នាំ NTFP ត្រូវបានធ្វើសវនកម្មដោយភ្នាក់នាសវនកម្ម ឯករាជ្យ។

- បន្ទាប់ពីអនុម័តគោលនយោបាយប្រឆាំងនឹងអំពើពុករលួយនេះ បុគ្គលិករបស់ NTFP ទាំងអស់ត្រូវបានតម្រូវឱ្យចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍អះអាងថាខ្លួនព្រមទទួលយកឯកសារនេះជាការណែនាំទូទៅក្នុងការការអនុវត្តការងារប្រចាំថ្ងៃ។

- NTFPលើកស្ទួយតម្លាភាពក្នុងសកម្មភាពរបស់ខ្លួន។ ផែនការងារប្រចាំឆ្នាំ និងគំរោងថវិកាប្រចាំឆ្នាំត្រូវបានបែងចែកឱ្យទៅភាគីពាក់ព័ន្ធសំខាន់ៗ ដូចមានកំណត់ក្នុងរបាយការណ៍ស្តីពីផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។ ម៉្យាងវិញទៀត អង្គការNTFP ក៏មានការប្រតិបត្តិដោយតម្លាភាពនូវកិច្ចការលទ្ធកម្មផងដែរ។

៣.២ សកម្មភាពរបស់កម្មវិធី

តារាងខាងក្រោមនេះបង្ហាញអំពីឧទាហរណ៍នៃវិស័យដែលអំពើពុករលួយអាចនឹងកើតមានឡើង និងវិធានការដែលNTFPបានប្រកាន់យក ឬនឹងប្រកាន់យកដើម្បីបង្ការអំពើពុករលួយ។ ឧទាហរណ៍ទាំងនេះមិនត្រូវចាត់ទុកថាជាឧទាហរណ៍ទាំងអស់ឡើយ។ តារាងជួរទី១ បញ្ជាក់អំពីសកម្មភាព និងភាពគ្រោះថ្នាក់។ ជួរទី២ បញ្ជាក់អំពីវិធានការដែល NTFP ចាត់ការដើម្បីបន្ថយគ្រោះថ្នាក់ទាំងនោះ និងជួរទី៣ បញ្ជាក់អំពីបុគ្គលឬអង្គការដែលទទួលខុសត្រូវអនុវត្តសកម្មភាពទាំងនេះ និងត្រួតពិនិត្យថាតើវិធានការនោះអនុវត្តបានត្រឹមត្រូវ និងពេញលេញដែរឬទេ។

| ហានិភ័យ | តើត្រូវទប់ស្កាត់វាដោយវិធីណា? | អ្នកទទួលខុសត្រូវ |
|---|---|---|
| A. ដំណើរការលទ្ធកម្ម(មានចែងនៅក្នុងគោលនយោបានរដ្ឋបាលនិងហិរញ្ញវត្ថុ) | | |
| ហានិភ័យទី១:<br>ការក្លែងបន្លំលើវិក័យប័ត្រ | a). គ្រប់វិក័យប័ត្រទាំងអស់ត្រូវតែ<br>-មានឈ្មោះអាសយដ្ឋាននិងលេខទូរស័ព្ទរបស់អ្នកលក់រឺក្រុមហ៊ុន។<br>-មានកាលបរិច្ឆេទ,ការបរិយាយពីចំនួន,តម្លៃរាយនិងតម្លៃសរុប។ | បុគ្គលិកNTFPទាំងអស់ |

| | | |
|---|---|---|
| | -មានហត្ថលេខាអ្នកលក់និងអ្នកទិញ<br>b). យ៉ាងតិចណាស់តម្រូវអោយមានសម្រង់តម្លៃពាក់ន្លែងក្នុងការទិញសម្ភារៈដើម្បីធានាថាតម្លៃសមហេតុផលដែលអាចទទួលយកបាន។<br>c).មូលប្បទានប័ត្រ/ប័ណ្ណផ្ទេរប្រាក់ត្រូវបានប្រើប្រាស់សំរាប់ចំណាយពី,,,,ដុល្លារឡើងទៅ។តែទោះបីយ៉ាងណាសាច់ប្រាក់ក៏អាចប្រើប្រាស់បានទៅតាមតម្រូវការសំរាប់អ្នកផ្គត់ផ្គង់មួយចំនួនពេលដែលពួកត្រូវការមូលប្បទានប័ត្រ/ប័ណ្ណផ្ទេរប្រាក់។<br>d). បន្ទាប់ពីបានចំណាយរួចរាល់ឯកសារគឺបានពិនិត្យដោយអ្នកគ្រប់គ្រងនិងបុគ្គលិកផ្នែកហិរញ្ញវត្ថុ។ប្រសិនបើឯកសារទាំងនោះមានការក្លែងបន្លំ បុគ្គលិកត្រូវតែសងត្រលប់មកវិញនូវរាល់ការចំណាស់។ | |
| ហានិភ័យទី២:<br>ទំនាស់ផលប្រយោជន៍នៅក្នុងបន្ទុកនៃការទិញសម្ភារៈ | a). ជៀសវាងអ្នកផ្គត់ផ្គង់មានទំនាក់ទំនងជាមួយបុគ្គលិកNTFP ប៉ុន្តែបុគ្គលិកNTFPត្រូវជូនដំណឹងដNTFPពីការទំនាក់ទំនងរឺជាប់ | នាយកប្រតិបត្តិ,ប្រធានកម្មវិធី,និងបុគ្គលិកហិរញ្ញវត្ថុ |

| | | |
|---|---|---|
| | សាច់ញាតិមួយអ្នកផ្គត់ផ្គង់។ | |
| ហានិភ័យទី៣:<br>ប្រាក់កម្រៃអំណោយ | a). បុគ្គលិកគឺមិនត្រូវបានអនុញ្ញាតិអោយទទួលប្រាក់កម្រៃអំណោយពីអ្នកផ្គត់ផ្គង់ទេ។ពេលដែលអ្នកផ្គត់ផ្គង់បានផ្តល់កម្រៃជូន,បុគ្គលិកត្រូវតែសួរទៅអ្នកផ្គត់ផ្គង់អោយដាក់នៅក្នុងវិក័យប័ត្រជាតម្លៃនៃទំនិញរឺសេវាកម្ម។បុគ្គលិកគួសំគាល់ថាពីហេតុផលនៃការបញ្ចុះតម្លៃនេះនៅលើវិក័យប័ត្រ។ក្នុងករណីផ្តល់ជាអំណោយ, បុគ្គលិកត្រូវតែផ្តល់អំណោយនោះទៅផ្នែករដ្ឋបាល/គណនេយ្យ។ | បុគ្គលិកNTFPទាំងអស់ |
| B. ការជ្រើសរើសបុគ្គលិក | | |
| ហានិភ័យទី១: លក្ខខណ្ឌ/តួនាទីភារៈកិច្ចបានបង្កើតជាពិសេសសំរាប់បុគ្គលម្នាក់ហើយមានការងារដែលដាក់អោយធ្វើតិចតួចទាក់ទងនឹងកម្មវិធី។ | a).តួនាទីនិងភារៈកិច្ចសម្រាប់កិច្ចការទាំងអស់ត្រូវត្រូវបានដាក់បញ្ចាំងដោយបុគ្គលិកយ៉ាងហោចណាស់ពីរសមាជិក។<br>b). តួនាទីនិងភារៈកិច្ចត្រូវបានចែកនៅក្នុងអង្គការជាសាធារណះ។ | ប្រធានកម្មវិធី,ប្រធានគម្រោងនិងផ្នែកដឹកនាំរបស់អង្គការ។ |
| ហានិភ័យទី២: ការវាយតម្លៃនៃបេក្ខជនដោយមានការលំអៀងទៅលើនរណាម្នាក់។ | a).លក្ខខណ្ឌត្រូវច្បាស់លាស់ទាក់ទងនឹង"លក្ខណៈសម្បត្តិ" ដែលត្រូវបានប្រើជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសបេក្ខជនហើយលក្ខណៈវិនិច្ឆ័យទាំងនេះគឺបានធ្វើដោយឯករាជ្យយ៉ាងហោចណាស់ | សមាជិកគណៈកម្មការក្រុមគ្រប់គ្រង |

| | | |
|---|---|---|
| | មានសមាជិកបុគ្គលិកពីរនាក់។ b).ដំណើរការនៃការសម្ភាសន៍នេះ ត្រូវបានធ្វើឡើងដោយគណៈកម្មការនៃការជ្រើសរើស។ | |
| ហានិភ័យទី៣: ក្នុងកំឡុងពេលនៃការចរចារកិច្ចសន្យាការងារ, NTFPចរចារទាមទារអោយច្បាស់ពីតម្លៃនៃភាគរយ។ | ការចរចារកិច្ចសន្យាការងារជាមួយបេក្ខជនគឺត្រូវមានបុគ្គលិក NTFP ២នាក់ចូលរួម។ក្នុងករណីនៃការចរចារតាមអ៊ីមែល,គ្រប់អ៊ីមែលទាំងអស់ត្រូវតែចម្លងជូនលោកនាយក និងគណៈកម្មការគ្រប់គ្រង (Macom)។ | គណៈកម្មការគ្រប់គ្រង និងប្រធានកម្មវិធី/ប្រធានគម្រោង |
| C. ការអនុវត្តគម្រោង | | |
| 1. | | |
| Risk 1: | | |

## ៤. ទណ្ឌកម្ម

• ករណីមានការសង្ស័យសមហេតុផលពីអំពើពុករលួយណាមួយ បុគ្គលិកពាក់ព័ន្ធនឹងត្រូវអញ្ជើញដោយលិខិតលាយលក្ខណ៍អក្សរ ដើម្បីឱ្យពន្យល់អំពីការប្រើប្រាស់មូលនិធិ ជូនគណៈកម្មាធិការប្រតិបត្តិដែលមានសមាសភាពជ្រើសតាំងពីសមាជិកនានានៃគណៈកម្មាធិការប្រតិបត្តិ និងដឹកនាំដោយនាយកប្រតិបត្តិ។

• កិច្ចសន្យាការងារនៃបុគ្គលិកណាដែលត្រូវបានរកឃើញថាមានកំហុសទាក់ទងនឹងឥរិយាបទពុករលួយណាមួយ (ដូចបានកំណត់ខាងលើ) ត្រូវបានបញ្ចប់ជាបន្ទាន់។

• ក្រុមហ៊ុនដែលត្រូវបានរកឃើញថាមានទោសទាក់ទងនឹងអំពើពុករលួយ ការលួចបន្លំ និង / ឬការឃុបឃិតគ្នាណាមួយត្រូវដាក់ចូលក្នុងបញ្ជីខ្មៅដោយអង្គការNTFP។

- អ្នកផ្គត់ផ្គង់ទំនិញ និង/ឬសេវា ត្រូវបានច្រានចោល និងកិច្ចសន្យាត្រូវបានលុបចោល ប្រសិនបើមានការប្រតិបត្តិខុសច្បាប់ ឬអំពើពុករលួយណាមួយជាប់ពាក់ព័ន្ធនឹងការឱ្យរង្វាន់ ឬការអនុវត្តកិច្ចសន្យាណាមួយ។

- ប្រសិនបើការប្រព្រឹត្តិខុសណាមួយ ឬសញ្ញាណាមួយនៃអំពើពុករលួយត្រូវបានសង្ស័យលើនាយកប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាលនឹងត្រូវជូនដំណឹងជាបន្ទាន់ និងបើកការស៊ើបអង្កេតចំពោះករណីនេះ។

គោលនយោបាយនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល NTFP ក្នុងសម័យប្រជុំ

ថ្ងៃទី01ខែ.តុលា...ឆ្នាំ.2016..... នៅ.ការិយាល័យ រតនគិរី

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| ឡុង សេរី | ............ |
| នាយកប្រតិបត្តិ | ប្រធានក្រុមប្រឹក្សាភិបាល |